វគ្គបំប៉នសមត្ថភាព ត្រៀមបាក់ឌុប

# សំណេរតែងសេចក្តី

បង្រៀនដោយ វ៉ាន់ វី
ដេប៉ាតឺម៉ង់ភាសាវិទ្យា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

សប្តាហ៍ទី៣៖ ៩ មករា ២០២៥

# ខ្លឹមសារ

- អ្វីហៅថា តែងសេចក្តី ?
- ប្រភេទតែងសេចក្តី
- តែងសេចក្តីអត្ថាធិប្បាយពន្យល់
  - ប្រភេទនៃតែងសេចក្តី
  - លក្ខណៈនៃតែងសេចក្តី
  - គម្រោងតែងសង្ខេប
  - គម្រោងតែងលម្អិត

# ១- អ្វីហៅថា តែងសេចក្ដី?

- **តែងសេចក្ដី** < **តែង** “តាក់តែង” + **សេចក្ដី** “ដំណើរ ហេតុការណ៍ សាច់រឿង”
  => **តែងសេចក្ដី** គឺជាការរៀបចំតាក់តែងដំណើរ ហេតុការណ៍ សាច់រឿងអ្វីមួយ។

- និយាយឱ្យងាយយល់ទៅ **តែងសេចក្ដី** គឺជាការសរសេរ រៀបរាប់ បរិយាយ អធិប្បាយតាមលំដាប់លំដោយអំពីបញ្ហាក្នុងប្រធានបោទណាមួយឱ្យងាយស្ដាប់ ងាយយល់ ដោយសេចក្ដីពន្យល់នោះក្បោះក្បាយ ទូលំទូលាយ ដើម្បីឱ្យអ្នកអានងាយស្ដាប់ ងាយយល់ ឬមានចំណាប់អារម្មណ៍ ពេញចិត្តជាដើម។

# ២- ប្រភេទនៃតែងសេចក្ដី

គេអាចបែកតែងសេចក្ដីជា (ធ សោ, ១៩៩៣: ៣)៖

១- អត្ថាធិប្បាយ

- **អត្ថាធិប្បាយពន្យល់**
- អត្ថាធិប្បាយពិភាក្សា
- អត្ថាធិប្បាយប្រៀបធៀប
- អត្ថាធិប្បាយនិទស្សន៍ ឬស្រាយបំភ្លឺ

២- ពណ៌នាកថា

៣- និទានកថា

៤- កំណត់ហេតុ

៥- របាយការណ៍

៦- សុន្ទរកថា ។ល។

# ៣- អត្ថាធិប្បាយពន្យល់

- អ្វីហៅថា ប្រធានពន្យល់?
- ប្រធានពន្យល់ ជាប្រធានអត្ថាធិប្បាយមួយបែប ដែលតម្រូវឱ្យអ្នកសរសេរ**ពន្យល់ បកស្រាយ បង្ហាញ**ពីអ្វីមួយ ដោយភ្ជាប់ជាមួយនឹងអំណះអំណាងច្បាស់លាស់ ស្របតាមប្រធានបោទ។
- គេតម្រូវឱ្យយើងពន្យល់ទស្សនៈ សុភាសិត អក្សរសិល្ប៍...ដោយពង្រីកសេចក្ដីប៉ុណ្ណោះ ពុំមែនតម្រូវឱ្យវែកញែក រកខុសរកត្រូវ ដូចប្រធានពិភាក្សាទេ។

# ៣.១- ប្រភេទអត្ថាធិប្បាយពន្យល់

- លោក សែម សូរ, លោក ជោង ផែល និងអ្នកដទៃទៀត (១៩៧១) បានចែកប្រធានអត្ថាធិប្បាយពន្យល់ជា៣យ៉ាង៖

**១- បែបទូទៅ៖** និយាយពីបញ្ហាទូទៅក្នុងសង្គម

**២- បែបសុភាសិត៖** លើកឡើងពីពាក្យទំនឹមទំនៀម ពាក្យចាស់បុរាណ

**៣- បែបអក្សរសិល្ប៍៖** និយាយពីបញ្ហាក្នុងអក្សរសិល្ប៍ ។

# ៣.១- ប្រភេទអត្ថាធិប្បាយពន្យល់

- បំណែកនាយកដ្ឋានអភិវឌ្ឍកម្មវិធីក្យា (២០១៧: ៣-៤) បានបែងចែកប្រធានអត្ថាធិប្បាយពន្យល់ជា៣បែបដែរ តែឱ្យឈ្មោះខុសគ្នាខ្លះ ៖

  **១- បែបពន្យល់ទស្សនៈ**

  **២- បែបពន្យល់សុភាសិត ពាក្យស្លោក ឬពាក្យអប់រំ**

  **៣- បែបពន្យល់អក្សរសិល្ប៍ ។**

# ៣.២- លក្ខណៈអន្តាធិប្បាយពន្យល់

## ក- ឃ្លាបង្ហាញមតិប្រធាន

- ឃ្លាខាងដើមនៃមតិប្រធាន អាចបញ្ជាក់ថាជាប្រធានពន្យល់បានខ្លះដែរ។
- ឧទាហរណ៍៖
    - សុភាសិតមួយពែងថា “...”។
    - មុននឹងស្លាប់ តាចឹមផ្តាំចៅចិត្រថា “...”។
    - ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងថា “...”។

# ៣.២- លក្ខណៈអន្តាធិប្បាយពន្យល់

## ១- ឃ្លាចោទសួរ

- ឃ្លាចោទសួរ អាចបញ្ជាក់ថា ប្រធានមួយជាប្រធានពន្យល់បាន។
- ឧទាហរណ៍៖
  - តើសុភាសិតនេះមានន័យយ៉ាងណា?
  - តើពំនោលនេះមានខ្លឹមសារដូចម្ដេច?
  - តើប្រធាននេះអប់រំយើងដូចម្ដេចខ្លះ?
  - តើទស្សនៈនេះមានអត្ថន័យបែបណា?

# ៣.២- លក្ខណៈអត្ថាធិប្បាយពន្យល់

## គ- ឃ្លាបង្គាប់បញ្ជា

- ពាក្យបង្គាប់បញ្ជាខាងក្រោមនេះ អាចបញ្ជាក់ថាប្រធានមួយជាប្រធានពន្យល់៖
  - ចូរពន្យល់  ដោយលើកឧទាហរណ៍មកបញ្ជាក់។
  - ចូរបកស្រាយ ដោយលើកភស្តុតាងមកបង្ហាញ។
  - ចូរបង្ហាញ...។
  - ចូររៀបរាប់...។
  - ចូរអធិប្បាយ...។
  - ចូរស្រាយបំភ្លឺ...។

# ៣.៣- គម្រោងតែងសង្ខេប

- តែងសេចក្តីអត្ថាធិប្បាយពន្យល់ មាន ៣ ផ្នែក ដូចប្រធានផ្សេងទៀតដែរ ៖

  ១- សេចក្តីផ្តើម

  ២- តួសេចក្តី

  ៣- សេចក្តីបញ្ចប់

# ៣.៣- គម្រោងតែងសេចក្ដី

## ១- សេចក្ដីផ្ដើម

- លំនាំបញ្ហា
- បំណកស្រាយបញ្ហា
- បំណោទបញ្ហា

# ៣.៣- គម្រោងតែងសង្ខេប

## ២- តួសេចក្ដី

ក- ឃ្លាភ្ជាប់សេចក្ដី ពន្យល់ពាក្យគន្លឹះ

ខ- ពន្យល់ន័យប្រធាន

គ- បកស្រាយប្រធាន

- គំនិតគាំទ្រទី១៖ សេចក្ដីលម្អិត និងឧទាហរណ៍
- គំនិតគាំទ្រទី១៖ សេចក្ដីលម្អិត និងឧទាហរណ៍
- គំនិតគាំទ្រទី១៖ សេចក្ដីលម្អិត និងឧទាហរណ៍ ...

ឃ- សរុប

# ៣.៣- គម្រោងតែងសង្ខេប

## ៣- សេចក្តីបញ្ចប់

- វាយតម្លៃប្រធាន
- យោបល់ផ្ទាល់ខ្លួន

# ៣.៤- គម្រោងតែងលម្អិត

## ១- សេចក្ដីផ្ដើម

### ក- លំនាំបញ្ហា៖

- លំនាំបញ្ហា គឺជាការនាំឱ្យគេស្គាល់បញ្ហា ពោលគឺអ្នកសរសេរគប្បីនាំអ្នកអានឱ្យដឹងជុំវិញបញ្ហាប្រធាន តែពុំមែនជាការបកស្រាយទេ។ អ្នកសរសេរអាចនិយាយអំពីសង្គមរស់នៅ ឬអក្សរសិល្ប៍ជាដើម (ឬចំណោះដឹងទូទៅទាក់ទងនឹងប្រធាន)។

# ១- សេចក្តីផ្តើម

## ២- ចំណោលបញ្ហា៖

- ជាការបង្ហាញនូវបញ្ហារបស់ប្រធាន គឺលើកឡើងពីមតិរបស់ប្រធាន ហើយមុននឹងបង្ហាញពីមតិរបស់ប្រធាន គេអាចប្រើឃ្លាភ្ជាប់សេចក្តីមួយចំនួនដូចជា៖
  - *អាស្រ័យហេតុនេះហើយបានជាមានមតិមួយអះអាងថា "មតិប្រធាន" ។*
  - *មូលហេតុនេះហើយបានជាមានមតិលើកឡើងថា "មតិប្រធាន" ។*
  - *ហេតុនេះហើយទើបមានទស្សនៈយល់ឃើញថា "មតិប្រធាន" ។ ...*

# ១- សេចក្ដីផ្ដើម

## គ- ចំណោទបញ្ហា៖

- នៅក្នុងចំណោទបញ្ហា អ្នកធ្វើតែងសេចក្ដីត្រូវចោទសួរតាមលក្ខណៈរបស់ប្រធានពន្យល់ ពោលគឺគេអាចចោទសួរដូចខាងក្រោម៖
  - *តើមតិខាងលើនេះមានន័យដូចម្ដេច?*
  - *តើទស្សនៈខាងលើនេះមានអត្ថន័យដូចម្ដេចខ្លះ?*
  - *តើពំនោលខាងលើនេះមានខ្លឹមសារយ៉ាងណាខ្លះ?...*

# ២- តួសេចក្តី

## ក- ឃ្លាភ្ជាប់សេចក្តី និងពន្យល់ពាក្យគន្លឹះ

- ក្នុងផ្នែកនេះ គេចាំបាច់ប្រើឃ្លាភ្ជាប់សេចក្តីដើម្បីភ្ជាប់ពីផ្តើមសេចក្តីមកតួសេចក្តី រួចទើបគេពន្យល់ពាក្យគន្លឹះសំខាន់ៗដែលមានក្នុងមតិប្រធាន។
- ឃ្លាភ្ជាប់សេចក្តីដែលគេនិយមប្រើមាន៖
  - *មុននឹងបកស្រាយប្រធានខាងលើ យើងគប្បីយល់ន័យរបស់ពាក្យ "..." ជាមុនសិន។*
  - *ដើម្បីបំភ្លឺប្រធានខាងលើឱ្យបានច្បាស់លាស់ យើងគួរយល់ន័យរបស់ពាក្យគន្លឹះជាមុនសិន។ ពាក្យ "..." មានន័យថា... ។ ឯពាក្យ "..." សំដៅដល់... ។*

# ២- តួសេចក្ដី

## ខ- ពន្យល់ន័យប្រធាន៖

- ក្នុងចំណុចនេះ អ្នកសរសេរត្រូវពន្យល់ន័យប្រធានឱ្យងាយយល់ ដោយយកពាក្យគន្លឹះដែលបានពន្យល់មកសម្រាយន័យប្រធានឱ្យសមស្រប ឱ្យអាចស្ដាប់បានជាការស្រេច។
- គេអាចប្រើឃ្លាមួយចំនួនដូចខាងក្រោម៖
  - *ដូចនេះ មតិប្រធាន(គំនិត យោបល់ ទស្សនៈ)ខាងលើ ចង់បានន័យថា ...។*
  - *ដូច្នេះ មតិប្រធាន(គំនិត យោបល់ ទស្សនៈ) ដែលបានលើកឡើងខាងលើ មានន័យថា ...។*

# ២- តួសេចក្ដី

## គ- បកស្រាយប្រធាន៖

- ក្នុងផ្នែកនេះ អ្នកសរសេរត្រូវបកស្រាយមតិប្រធាន ដោយមានគំនិតសំខាន់ សេចក្ដីលម្អិត និងឧទាហរណ៍។
- ក្នុងករណីប្រធានមានលក្ខណៈទូទៅ គ្មានលក្ខខណ្ឌជាក់លាក់ទេ អ្នកធ្វើតែងសេចក្ដីត្រូវសរសេរបកស្រាយឱ្យទាក់ទងនឹងអ្វីជាទូទៅដែរ អាចនិយាយពីសង្គម ឬអក្សរសិល្ប៍ជាដើម។ ប៉ុន្តែ បើប្រធានមានលក្ខខណ្ឌច្បាស់លាស់ ត្រូវបកស្រាយតាមពាក្យបង្គាប់បញ្ជា ដើម្បីកុំឱ្យបាកប្រធាន។

# ២- តួសេចក្ដី

## គ- បកស្រាយប្រធាន៖

- ដើម្បីបកស្រាយប្រធានបានល្អ គេត្រូវយកគំនិតសំខាន់ មកពន្យល់ម្ដងមួយចំណុចៗ ដោយលើកឧទាហរណ៍មកបញ្ជាក់ឱ្យបានច្បាស់លាស់ ដូចខាងក្រោម៖
  - គំនិតសំខាន់ទី១៖ សេចក្ដីលម្អិត និងឧទាហរណ៍
  - គំនិតសំខាន់ទី២៖ សេចក្ដីលម្អិត និងឧទាហរណ៍
  - គំនិតសំខាន់ទី៣៖ សេចក្ដីលម្អិត និងឧទាហរណ៍...
- ក្នុងចំណុចឧទាហរណ៍នីមួយៗ អ្នកសរសេរអាចប្រើពាក្យភ្ជាប់សេចក្ដីដូចជា៖
  - *ជាក់ស្ដែង...*
  - *ជាតួយ៉ាង*

# ២- តួសេចក្តី

## ឃ- សរុប

- សរុបគឺជាផ្នែកមួយដែលគេត្រូវសរុបខ្លឹមសាររបស់តួសេចក្តីឱ្យខ្លីល្មម និងមានន័យក្តោបតួសេចក្តីទាំងមូល។ ក្នុងចំណុចនេះគេអាចប្រើពាក្យ ឬឃ្លាភ្ជាប់សេចក្តីមួយចំនួនដូចជា៖
  - *សរុបមក... ។*
  - *សរុបសេចក្តីទៅ... ។*
  - *រួមសេចក្តីមក... ។*
  - *ជារួមមក... ។*

# ៣- សេចក្ដីបញ្ចប់

## ក- វាយតម្លៃប្រធាន

- គឺជាការឱ្យតម្លៃទៅលើប្រធានដែលគេបានសិក្សារួចមកហើយនៅខាងលើជា "មានខ្លឹមសារ ឬមានអត្ថន័យល្អ" ជាដើម។
- ក្នុងចំណុចនេះ គេនិយមប្រើឃ្លាភ្ជាប់សេចក្ដី ៖
  - *តាមការបកស្រាយមតិខាងលើ យើងឃើញថា ទស្សនៈនេះ ឬគំនោលនេះ... ។*
  - *ឆ្លងតាមការបកស្រាយខាងលើ ដោយមានឧទាហរណ៍ផងនោះ យើងអាចនិយាយបានថា ... ។*
  - *ការបកស្រាយមតិ(ឬទស្សនៈ)ខាងលើ បានបង្ហាញឱ្យឃើញថា... ។*

# ៣- សេចក្ដីបញ្ចប់

## ១- យោបល់ផ្ទាល់ខ្លួន

- អ្នកធ្វើតែងសេចក្ដី គប្បីបញ្ចេញយោបល់ផ្ទាល់ខ្លួនទៅលើមតិប្រធានឱ្យបានច្បាស់។ យោបល់នោះត្រូវស្ថិតក្នុងគោលបំណងដ៏ប្រសើរមួយ គឺឆ្ពោះទៅរកការអប់រំ និងផ្អែកលើមូលដ្ឋានវិទ្យាសាស្ត្រ និងការជឿនលឿន។
- ក្នុងចំណុចនេះ គេនិយមប្រើពាក្យ ឬឃ្លាភ្ជាប់សេចក្ដី៖
  - *ដូច្នេះ យើងជា...*
  - *ដូច្នេះ ក្នុងនាមយើងជា...*
  - *អាស្រ័យហេតុនេះ យើងម្នាក់ៗ...*

# ប្រធានគំរូ

**ប្រធាន៖** ការអភិវឌ្ឍប្រទេសជាតិឱ្យរីកចម្រើនប្រកបដោយសុខសន្តិភាពពិតជាពុំអាចផ្ដាច់ចេញពីការបណ្ដុះបណ្ដាលធនធានមនុស្សបានឡើយ។ ក្នុងស្ថានភាពបច្ចុប្បន្ន តើត្រូវបណ្ដុះបណ្ដាលធនធានមនុស្សឱ្យមានលក្ខណសម្បត្តិដូចម្ដេច?

# ឯកសារពិគ្រោះ


- កាន់ ចាន់ដារ៉ា និង វ៉ាន់ វី ***តែងសេចក្ដី៖ ប្រធានពន្យល់*** ភ្នំពេញ ឆ្នាំ២០១២។
- ធ សោ ***វិធីសាស្ត្រនៃការធ្វើតែងសេចក្ដី*** (ឯកសារប្រើប្រាស់ផ្ទៃក្នុង) សាកលវិទ្យាល័យភ្នំពេញ ឆ្នាំ១៩៨៣។
- នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ***វិធីសាស្ត្រនៃការសរសេរតែងសេចក្ដី*** *(សម្រាប់មធ្យមសិក្សាទុតិយភូមិ)* ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៧។
- នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ***វិធីសាស្ត្រនៃការសរសេរតែងសេចក្ដី*** *(សម្រាប់មធ្យមសិក្សាបឋមភូមិ)* ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៨។
- វង្ស មេង និង អ្នកដទៃ ***វេយ្យាករណ៍ភាសាខ្មែរ*** វិទ្យាស្ថានភាសាបរទេសនៃស.ភ.ភ.ព. ឆ្នាំ២០១៣។
- វ៉ាន់ វី និង សំ អេងលាង ***ជំនាញសរសេរ*** ភ្នំពេញ ឆ្នាំ២០២៤។
- សែម សួរ, ថោង ធែល និងអ្នកដទៃទៀត ***វិញ្ញាសាតែងសេចក្ដីគំរូ*** បណ្ណាគារមាយើង ឆ្នាំ១៩៧១។